# ក្រុមហ៊ុន ស៊ុន ស៊ីន ឡាក់ហ្គេដអ៊ីនដាសស្ទ្រី (ខេមបូឌា) ឯ.ក

## 顺鑫箱包厂（柬埔寨）有限公司

## SHUNXIN LUGGAGE INDUSTRY (CAMBODIA) CO, LTD

អាសយដ្ឋាន: អគារលេខ ១៦ ផ្លូវជាតិលេខ ៥ ភូមិស្ពានពោធិ៍ ឃុំសេដ្ឋី ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ព្រះរាជាណាចក្រកម្ពុជា chanpiseymommy@gmail.com

---

### កិច្ចព្រមព្រៀងស្តីពី

### ការព្យួរកិច្ចសន្យាការងារដោយបញ្ហាសេដ្ឋកិច្ច (គ្មានការបញ្ជាទិញ)

កិច្ចព្រមព្រៀងនេះត្រូវបានព្រមព្រៀងធ្វើឡើងរវាងរោងចក្រ **ស៊ុន ស៊ីន ឡាក់ហ្គេដ អ៊ីនដាសស្ទ្រី (ខេមបូឌា) ឯ.ក** និង ថ្នាក់ដឹកនាំ **តំណាងកម្មករ ប្រចាំរោងចក្រ និយោជិត (ប្រតិភូបុគ្គលិកពេញសិទ្ធិ)** នៃរោងចក្រ ស៊ុន ស៊ីន ឡាក់ហ្គេដ អ៊ីនដាសស្ទ្រី (ខេមបូឌា) ឯ.ក ដោយបាន ព្រមព្រៀងគ្នាទាំងស្រុងលើការព្យួរកិច្ចសន្យាការងារដោយមូលហេតុៈ បញ្ហាសេដ្ឋកិច្ច (គ្មានការបញ្ជាទិញ) ដែលភាគីទាំងពីរបាន ព្រមព្រៀងគ្នាទៅតាមលក្ខខណ្ឌ និង យោងទៅតាមមាត្រា៧១-៧២ នៃច្បាប់ស្តីពីការងារព្រះរាជាណាចក្រកម្ពុជា និងសេចក្តីណែនាំ លេខៈ ០២០/២៣ ក.ប/ស.ណ.ន.១.ល ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ ២០២៣ ដូចខាងក្រោមៈ

1) ព្រមព្រៀងព្យួរកិច្ចសន្យាការងារចំពោះកម្មករ និយោជិតចំនួន ១៥៧នាក់ (ស្រី ១០៨) ចំនួន ៣០ថ្ងៃ ដោយអនុវត្តចាប់ពីថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២៣។
2) នៅក្នុងកំឡុងពេលនៃការព្យួរកិច្ចសន្យាការងារនេះ ភាគីនិយោជកយល់ព្រមផ្តល់អោយនូវៈ
   a) ប្រាក់ឧបត្ថម្ភចំនួន ១៥ ដុល្លាអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ទៅ ១៤ថ្ងៃ
   b) ប្រាក់ឧបត្ថម្ភចំនួន ៣០ ដុល្លាអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១៥ថ្ងៃ ទៅ ១ខែ
   c) ប្រាក់ឧបត្ថម្ភខាងលើនឹងបើកផ្តល់ជូនកម្មករ និយោជិតនៅថ្ងៃទី២៦ ខែមិថុនា ២០២៣
3) កិច្ចព្រមព្រៀងនេះមានសុពលភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខា និង ផ្តិតស្នាមម្រាមដៃនេះតទៅ។

ថ្ងៃអង្គារ៍ ៥កើត ខែ ជេស្ឋ ឆ្នាំថោះ ចត្វាស័ក ព.ស. ២៥៦៧

កំពង់ឆ្នាំង ថ្ងៃទី 23 ខែ ឧសភា ឆ្នាំ២០២៣

**តំណាងកម្មករ(ភាគនិយោជិត)**

**តំណាងរោងចក្រ(ភាគនិយោជក)**

**ញឿង នោនី** **ម៉ន ផល្លា** **ផាំ សារស់** **ព្រឿង ចុល** **ហម មញ្ញា**

**ម៉ិច ចន្ធូ** **សុខ ចន្ថា** **សុខ ស្រីលីន** **ចន សាមន** **អុន ស្រីនាង**

KINGDOM OF CAMBODIA

Mr.ZHOU DEHU